00505865

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification):
30 / 04 / 2010
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

C26/5/12

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ

សំណុំរឿងព្រហ្មទណ្ឌលេខៈ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ៣៦)

ចំពោះមុខៈ ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉ីយ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 30 / 04 / 2010
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ក្រឡាបញ្ជីៈ ឈុន ព្រលឹង
Entela JOSIFI

កាលបរិច្ឆេទៈ ៣០ ខែ មេសា ឆ្នាំ២០១០

## សាធារណៈ(ដោយកោសលុប)
## សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចលើការបន្តរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន

សហព្រះរាជអាជ្ញា
ជា លាង
Andrew CAYLEY
យ៉េត ចរិយា
William SMITH
ពេជ សម្បត្តិ
Tarik ABDULHAK

ជនត្រូវចោទ
ខៀវ សំផន

00505866

002/19-09-2007-អវតក/កសចស (អបជ៣៦)

លេខ/No.C26/9/12

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

នី ចាន់ឌី

Mahdev MOHAN
Lyma NGUYEN

គឹម ម៉េងឃី

ម៉ុច សុវណ្ណារី

Elizabeth-Joelle RABESANRATANA
Annie DELAHAIE
Philippe CANONNE
Martine JACQUIN
Fabienne TRUSSES-NAPROUS
Ms. Françoise GAUTRY
Ms. Isabelle DURAND
Ms. Christine MARTINEAU
Ms. Laure DESFORGES
Mr. Ferdinand DJAMMEN

ឡោ ជុនធី

ស៊ិន សុវ៉ន

សំ សុខគង់

ហុង គឹមសួន

គង់ ពិសី

គង់ ហេង

Silke STUDZINSKY
Olivier BAHOUGNE
Marie GUIRAUD
Patrick BAUDOUIN

ជេត វណ្ណលី

ពេជ អង្គ

Julien RIVET
Pascal AUBOIN

**សហមេធាវីការពារក្តីជនត្រូវចោទ**

ស ស្វវ៉ាន

Jacques VERGÉS

00505867

១. **អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("**អ.វ.ត.ក**") បានទទួលបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការពន្យារថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ដែលសហមេធាវីការពារក្តី **ខៀវ សំផន** បានប្តឹងនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៨ ("បណ្តឹងឧទ្ធរណ៍")[១]។

## I. ប្រវត្តិនីតិវិធី

២. អង្គបុរេជំនុំជម្រះយោងទៅលើរបាយការណ៍ស្តីពីការត្រួតពិនិត្យសំណុំរឿង[២] ដែលត្រូវបានពិនិត្យ និងអនុម័តកាលពីថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១០ ដែលបង្កើតជាផ្នែកមួយនៃសាលដីកានេះ។

៣. នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ("ដីកាសម្រេចបន្តថិរវេលា") ដោយបានសម្រេចបន្តការឃុំខ្លួនបណ្តោះអាសន្នបន្តទៀតលើ **ខៀវ សំផន** ដែលបានជាប់ឃុំបណ្តោះអាសន្នចាប់តាំងពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧[៣]។

៤. នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៨ សហមេធាវីការពារក្តីជនត្រូវចោទបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ ហើយនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៨ សហមេធាវីការពារក្តីបានដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួន ដែលបណ្តឹងឧទ្ធរណ៍នេះបានជូនដំណឹងដល់ភាគីទាំងអស់នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៨។

៥. នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១០ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍ ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា")[៤]។

៦. ដើមបណ្តឹងរដ្ឋប្បវេណីមិនបានដាក់សេចក្តីសន្និដ្ឋានតបឡើយ។

---

[១] សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើការពន្យារថិរវេលាឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ C26/9/1 ។

[២] របាយការណ៍ស្តីពីការត្រួតពិនិត្យសំណុំរឿង ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ C26/9/6 ។

[៣] ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ C26/8 ។

[៤] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១០ ឯកសារ C26/9/2 ។

00505868



៧. នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០១០ ប្រធានអង្គបុរេជំនុំជម្រះបានចេញដីកាកំណត់កាលបរិច្ឆេទបើកសវនាការជាសាធារណៈលើបណ្តឹងឧទ្ធរណ៍នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០[៥]។ នៅមុនពេលសវនាការ អង្គបុរេជំនុំជម្រះបានទទួលលទ្ធភាពពិនិត្យសំណុំរឿង ដែលបានធ្វើបច្ចុប្បន្នភាពរួចហើយ។

៨. នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះបានបើកសវនាការជាសាធារណៈមួយ ដែលជនត្រូវចោទមានសហមេធាវីជាតិរបស់ខ្លួនតំណាង។សហមេធាវីអន្តរជាតិរបស់ជនត្រូវចោទអវត្តមាន។

## II. ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

៩. ដីកាបន្តថិរវេលាបានចេញនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩ ហើយបានជូនដំណឹងដល់គ្រប់ភាគីជាភាសាបារាំងនៅថ្ងៃនោះតែម្តង។ សហមេធាវីការពារក្តីជនត្រូវចោទបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ហើយបណ្តឹងឧទ្ធរណ៍បានដាក់ប្តឹងនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩។ ដូច្នេះ បណ្តឹងឧទ្ធរណ៍នេះបានធ្វើឡើងក្នុងរយៈពេលកំណត់ដូចដែលបានចែងនៅក្នុងវិធាន ៧៥(៣)នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (“វិធានផ្ទៃក្នុង”)។

## III. ច្បាប់ជាធរមាន

១០. បណ្តឹងឧទ្ធរណ៍នេះយោងលើវិធាន ៦៣ នៃវិធានផ្ទៃក្នុង។

## IV. លក្ខណៈនៃបណ្តឹងឧទ្ធរណ៍

១១. យោងតាមបណ្តឹងឧទ្ធរណ៍ សហមេធាវីការពារក្តីបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះដោះលែងជនត្រូវចោទពីការឃុំខ្លួនបណ្តោះអាសន្ន[៦]។ សហមេធាវីការពារក្តីបានអះអាងថា សហចៅក្រមស៊ើបអង្កេតមិនបានផ្តល់សម្អាងហេតុក្នុងការផ្តល់យុត្តិកម្ម លើការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះ

[៥] ដីកាកំណត់កាលបរិច្ឆេទសវនាការ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១០ ឯកសារ C26/9/3 ។

[៦] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៤, ៣៤ ។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

អាសន្នឡើយ[៧]។ សហមេធាវីការពារក្តីក៏បានសន្និដ្ឋានទៀតថា សហចៅក្រមស៊ើបអង្កេតមិនបាន "ឆ្លើយតបទៅនឹងទឡ្ហីករណ៍របស់ក្រុមមេធាវីការពារក្តី ទាក់ទងនឹងការរំលោភបំពានជាប្រព័ន្ធលើសច្ចធារណ៍និរទោស និងសិទ្ធិទាំងឡាយរបស់ **ខៀវ សំផន**" ហើយសហចៅក្រមស៊ើបអង្កេតបានច្រានចោលការរកឃើញលើកមុនរបស់អង្គបុរេជំនុំជម្រះថា "កិច្ចដំណើរការនីតិវិធីទាំងមូល" ត្រូវតែធ្វើការត្រួតពិនិត្យនៅពេលពិចារណាថា តើរយៈពេលនៃការឃុំខ្លួនបណ្តោះមានភាពសមស្របដែរឬយ៉ាងណា"[៨]។

១២. នៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាបានស្នើសុំអង្គបុរេជំនុំជម្រះឱ្យច្រានចោលបណ្តឹងឧទ្ធរណ៍ទុកជាឥតបានការ ដោយឈរលើមូលដ្ឋានថា៖ (១) ដីកាសម្រេចបន្តចិរវេលាបានផ្តល់មូលហេតុគ្រប់គ្រាន់ និងសមល្មម, (២) ដើមបណ្តឹងឧទ្ធរណ៍បានខកខានក្នុងការបង្ហាញឱ្យឃើញអំពីការកែប្រែនៃកាលៈទេសៈជាក់ស្តែងណាមួយ ចាប់តាំងពីដើមបណ្តឹងឧទ្ធរណ៍ត្រូវបានឃុំខ្លួនពីដំបូង, (៣) រយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នមិនមែនមិនមានហេតុផលនោះទេ ហើយសហចៅក្រមស៊ើបអង្កេតបានបំពេញកិច្ចស៊ើបសួរដោយយកចិត្តទុកដាក់ហ្មតចត់ ដោយមានការគោរពសិទ្ធិសច្ចធារណ៍និរទោសរបស់ដើមបណ្តឹងឧទ្ធរណ៍, (៤) ការតវ៉ារបស់ដើមបណ្តឹងឧទ្ធរណ៍អំពីភាពលម្អៀងជាប្រព័ន្ធរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបានអង្គបុរេជំនុំជម្រះរកឃើញថាមិនត្រឹមត្រូវ, ហើយ (៥) ការតវ៉ាច្រំដែលរបស់ដើមបណ្តឹងឧទ្ធរណ៍ដែលថា ខ្លួនគ្មានលទ្ធភាពដោយប្រសិទ្ធិភាពដើម្បីរកភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿង ត្រូវបានដោះស្រាយរួចហើយ នៅពេលដែលអង្គបុរេជំនុំជម្រះតម្កល់ដីកាសម្រេចទាក់ទិននឹងសិទ្ធិ និងកាតព្វកិច្ចនៃការបកប្រែរបស់គូភាគី ទុកជាបានការ[៩]។

[៧] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៣, ៧ ។

[៨] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៣១ (គូសបញ្ជាក់លើច្បាប់ដើម)

[៩] ចម្លើយតបរបស់សហព្រះរាជាអាជ្ញា កថាខណ្ឌ ៣ កថាខណ្ឌរង ក-ង ។

១៣. ដោយពិចារណាលើសេចក្តីសម្រេចទាំងឡាយរបស់ខ្លួន ទាក់ទងនឹងបញ្ហាឃុំខ្លួន[១០] និងសេចក្តីសន្និដ្ឋានរបស់ភាគីដូចបានលើកឡើងនៅក្នុងរបាយការណ៍ស្តីពីការត្រួតពិនិត្យសំណុំរឿង អង្គបុរេជំនុំជម្រះនឹងពិនិត្យមើលដីកាសម្រេចបន្តថិរវេលាសារជាថ្មី ត្រង់ចំណុច៖

ក. មូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (វិធាន ៦៣(៣)(ក)នៃវិធានផ្ទៃក្នុង)។

ខ. មូលដ្ឋានដែលធ្វើឱ្យការឃុំខ្លួនបណ្តោះអាសន្នជាវិធានការដ៏ចាំបាច់មួយ(វិធាន ៦៣(៣)(ខ)នៃវិធានផ្ទៃក្នុង) ។

គ. ការយកចិត្តទុកដាក់នៅក្នុងការបំពេញកិច្ចស៊ើបសួរ។

ឃ. សំណើសុំដោះលែងដោយដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ

## V. **ការពិចារណា**

**ក. មូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ (វិធាន ៦៣(៣)(ក)នៃវិធានផ្ទៃក្នុង)៖**

១៤. យោងតាមដីកាសម្រេចបន្តថិរវេលា សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ឃើញថា មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា **ខៀវ សំផន** ធ្លាប់បានប្រព្រឹត្តឧក្រិដ្ឋកម្ម

[១០] សាដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៨ ឯកសារ C9/4/7។ សាលដីកាបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ២០០៨ ឯកសារ C80/5/18។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០០៨ ឯកសារ C22/5/38 និង សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ខៀវ សំផន ប្រឆាំងនឹងដីកាបដិសេធលើសំណើសុំដោះលែងឲ្យមានសេរីភាព និងដីកាសម្រេចពន្យារថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៨ ឯកសារ C26/5/26។



ECCC * CETC * PRE-TRIAL CHAMBER

00505871



ទាំងឡាយដែលដាក់បន្ទុកលើខ្លួន[១១] ដូចមានបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួន ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ ដែលក្នុងនោះបដិសេធសំណើសុំដោះលែងឱ្យមានសេរីភាព[១២] ដីកាសម្រេចបន្តថិរវេលាឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្នចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៨[១៣] និងសាលដីការបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ លើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចទាំងពីរនេះ[១៤]។

១៥. សហចៅក្រមស៊ើបអង្កេតកត់សម្គាល់ឃើញទៀតថា៖

> "ចាប់តាំងពី[ថ្ងៃសវនាការលើបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០០៩ មក] សហចៅក្រមស៊ើបអង្កេតបានបន្តអង្កេតលើការចោទប្រកាន់ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដាក់ភស្តុតាងទៅក្នុងសំណុំរឿង។ ចម្លើយសាក្សីថ្មីច្រើនជាងសាមសិបត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងដែលជួយបញ្ជាក់តើថា ជនត្រូវចោទដើរតួនាទីជាប់ពាក់ព័ន្ធយ៉ាងណានឹងបទឧក្រិដ្ឋ ដូចដែលបានចោទប្រកាន់..."[១៥]

១៦. នៅក្នុងកថាខណ្ឌដដែលនេះ សហចៅក្រមស៊ើបអង្កេតបានបន្តរៀបរាប់ឧក្រិដ្ឋកម្មទាំងឡាយ និងបានដកស្រង់ភស្តុតាង ដែលទំនងជាបង្ហាញអំពីការចោទប្រកាន់ចំពោះការជាប់ពាក់ព័ន្ធរបស់ជនត្រូវចោទទៅនឹងឧក្រិដ្ឋកម្មទាំងនោះ[១៦]។

១៧. សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានថា៖

---

[១១] ដីកាសម្រេចបដិសេធសំណើសុំដោះលែងឱ្យមានសេរីភាព ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៨ ឯកសារ C40/4។

[១២] ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៨ ឯកសារ C26/4។

[១៣] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទ ខៀវ សំផន ប្រឆាំងនឹងដីកាបដិសេធលើសំណើសុំដោះលែងឱ្យមានសេរីភាព និងដីកាសម្រេចពន្យារថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ឯកសារ C26/5/2 (សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ពីររបស់ ខៀវ សំផន)។

[១៤] ដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន កថាខណ្ឌ១៥-១៦។

[១៥] ដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន កថាខណ្ឌ១៨ (សម្រង់ខាងក្នុងត្រូវបានលុបចោល)។

[១៦] ដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន កថាខណ្ឌ១៨។



E.C.C.C * C.E.T.C PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

"បន្ទាប់ពីបានពិនិត្យឡើងវិញលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង...នៅត្រឹមដំណាក់កាលនៃកិច្ចស៊ើបសួរនេះ មានការលេចឡើងនូវអង្គហេតុ និងព័ត៌មានបន្ថែមនានា ដែលអាចឱ្យអ្នកសង្កេតការណ៍អព្យាក្រឹត្យអាចជឿជាក់បានថា នៅក្នុងមុខងារ និងតួនាទីមួយ ឬច្រើនរបស់គាត់ ដូចបានបង្ហាញខាងលើ **ខៀវ សំផន** បានរៀបចំផែនការ ញុះញង់ បញ្ជា មិនបានព្យាយាមទប់ស្កាត់ ឬ ជួយ និងជម្រុញឱ្យមានការប្រព្រឹត្តបទឧក្រិដ្ឋកម្មនានា ដូចមានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ជាហេតុនាំឱ្យលក្ខខណ្ឌដែលមានកំណត់នៅក្នុងវិធាន ៦៣(៣)(ក)នៃវិធានផ្ទៃក្នុង...នៅតែត្រូវបានបំពេញ ចាប់តាំងពីពេលជនរូបនេះត្រូវបានឃុំខ្លួនបណ្ដោះអាសន្ន ទោះបីជាមានការកន្លងផុតទៅនៃពេលវេលាក្តី"[១៧]។

១៨. សហមេធាវីការពារក្ដីបានលើកឡើងនៅក្នុងបណ្ដឹងឧទ្ធរណ៍របស់ខ្លួនថា សហចៅក្រមស៊ើបអង្កេតបានរំលោភបំពានលើគោលការណ៍សច្ចធារណ៍និរទោស នៅពេលធ្វើការបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ពីព្រោះតែបញ្ហាចម្បងនោះគឺ សហចៅក្រមស៊ើបអង្កេត "មិនបានរកឃើញការផ្លាស់ប្តូរកាលៈទេសៈណាមួយ" ចាប់តាំងពីពេលចេញសាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចបន្តថិរវេលា កាលពីលើកមុន[១៨]។ សហមេធាវីការពារក្ដីបានអះអាងថា អនុលោមតាមវិធាន ៦៣(៧) នៃវិធានផ្ទៃក្នុង សហចៅក្រមស៊ើបអង្កេតទទួលបន្ទុកដោយផ្ទាល់ក្នុងការបង្ហាញឱ្យបានស៊ីសង្វាក់អំពីកត្តាទាំងឡាយដែលពាក់ព័ន្ធនឹងការឃុំខ្លួនបណ្ដោះអាសន្ន[១៩]។ សហមេធាវីការពារក្ដីបានសន្និដ្ឋានបន្ថែមទៀតថា សហចៅក្រមស៊ើបអង្កេតបានកំណត់អត្តសញ្ញាណនៃភស្តុតាងដោះបន្ទុកមួយចំនួននៅក្នុងសំណុំរឿង ប៉ុន្តែមិនបានវាយតម្លៃភស្តុតាងទាំងនេះឱ្យបានសមរម្យដើម្បីឱ្យស្របទៅតាមយុត្តិសាស្ត្រអន្តរជាតិ និងបទដ្ឋាននានា ដូចបានកំណត់នៅក្នុងវិធាន ៦៣(៣)(ក) នៃវិធានផ្ទៃក្នុង និងដោយអង្គបុរេជំនុំជម្រះ[២០]។

[១៧] ដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន កថាខណ្ឌ២១។

[១៨] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ៧-៨។

[១៩] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ៧។

[២០] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ១០-១៣។

១៩. នៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា ក្រុមមេធាវីការពារក្តីបានដាក់បន្ទុកលើការបង្ហាញភស្តុតាងមិនសមស្រប ដល់សហចៅក្រមស៊ើបអង្កេត។ សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតគ្រាន់តែមានកាតព្វកិច្ច "ក្នុងការធ្វើការប៉ាន់ប្រមាណវាយតម្លៃឡើងវិញអំពីលក្ខណៈវិនិច្ឆ័យសម្រាប់ការបន្តការឃុំខ្លួនតទៅទៀត ត្រូវបានបំពេញគ្រប់គ្រាន់ហើយតែប៉ុណ្ណោះ"[២១] ហើយ"ក្រុមមេធាវីការពារក្តីទទួលបន្ទុកក្នុងការបង្ហាញភស្តុតាងថា កាលៈទេសៈបានផ្លាស់ប្តូរ ហើយ[លក្ខខណ្ឌទាំងឡាយនៅក្នុងអនុវិធាន ៦៣(៣) នៃវិធានផ្ទៃក្នុងមិនបានបំពេញទៀតទេ] ចាប់តាំងពីការចេញដីកាសម្រេចបន្តថិរវេលាឃុំខ្លួនចុងក្រោយបំផុត"[២២]។ សហព្រះរាជអាជ្ញាបានជំទាស់នឹងការសន្និដ្ឋានរបស់ក្រុមមេធាវីការពារក្តី ដែលបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតមិនបានយកចិត្តទុកដាក់លើភស្តុតាងដោះបន្ទុក។ ផ្ទុយនឹងចំណុចនេះ សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតបានកំណត់អត្តសញ្ញាណយ៉ាងច្បាស់ ហើយវាយតម្លៃយ៉ាងសមរម្យលើគ្រប់ភស្តុតាងទាំងអស់ ទាំងភស្តុតាងដោះបន្ទុក និងភស្តុតាងដាក់បន្ទុក នៅពេលផ្តល់សម្អាងហេតុរបស់ខ្លួននៅក្នុងដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន[២៣]។ សហព្រះរាជអាជ្ញាក៏បានលើកឡើងថា អង្គបុរេជំនុំជម្រះគួរតែពិចារណាលើគ្រប់ភស្តុតាងទាំងអស់ ដែលបានដាក់ជូនចាប់តាំងពីបណ្តឹងឧទ្ធរណ៍លើកមុន ដែលក្នុងនោះរួមមានការជូនដំណឹងអំពីបទចោទថ្មីៗ ដែលដាក់បន្ទុកលើជនត្រូវចោទ[២៤]។

២០. ចំពោះសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាលើបទចោទបន្ថែម អង្គបុរេជំនុំជម្រះសង្កេតឃើញថា ដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នបានចេញនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៩

[២១] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១០។

[២២] ប្រតិចារឹកនៃសវនាការលើបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ C26/9, ទំព័រ២៨ (សម្រង់សេចក្តីសម្រេចបណ្តឹងឧទ្ធរណ៍ពីររបស់ ខៀវ សំផន)។

[២៣] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១១-១៣។

[២៤] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ៨។

ហើយនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចមួយដើម្បីបំភ្លឺលើបទចោទទាំងឡាយដែលដាក់បន្ទុកលើជនត្រូវចោទ[២៥]។

២១. នៅពេលបង្ហាញខ្លួនលើកដំបូង ជនត្រូវចោទបានទទួលការជូនដំណឹងថា ខ្លួនត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការចំពោះ "បទល្មើសប្រឆាំងនឹងមនុស្សជាតិ [...] និងការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាទីក្រុងហ្សឺណែវ [...] បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ"[២៦]។ នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ ក្នុងអំឡុងពេលសួរចម្លើយជនត្រូវចោទ សហចៅក្រមស៊ើបអង្កេតបានតម្កល់បទចោទទាំងនេះ ហើយក៏បានជូនដំណឹងដល់ជនត្រូវចោទ និងសហមេធាវីការពារក្តីជននេះអំពីបទចោទបន្ថែមដែលអាចចោទប្រកាន់លើជននេះ ក្នុងនោះរួមមាន"បទប្រល័យពូជសាសន៍ និងបទល្មើសក្រោមច្បាប់ជាតិ"[២៧]។

២២. ដើម្បីជាផលប្រយោជន៍យុត្តិធម៌ អង្គបុរេជំនុំជម្រះចង្អុលយោងលើសាលដីកាលើកមុនរបស់ខ្លួនដែលបានសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅក្នុងសំណុំរឿងលេខ០០១ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ")[២៨]។ អង្គបុរេជំនុំជម្រះបានរកឃើញថា នៅពេលដែលមានធាតុផ្សំនៃអង្គហេតុដូចគ្នាបេះបិទ ទើបគេអាចអះអាងថា បទល្មើសផ្សេងបានបញ្ចូលនៅក្នុងបទចោទ ហើយប្រសិនបើធាតុផ្សំទាំងឡាយខុសគ្នាបទល្មើសផ្សេងមិនបានបញ្ចូលឡើយ[២៩]។ នៅក្នុងសាលដីកាដដែលនេះ អង្គបុរេជំនុំជម្រះបានរកឃើញថា ជាឧទាហរណ៍ បទល្មើសក្រោមច្បាប់ជាតិរួមមានធាតុផ្សំខុសពីបទល្មើសក្រោមច្បាប់

---

[២៥] ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យធ្វើការបំភ្លឺ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩ D198/1។ ដីកានេះត្រូវបានទទួល និងដាក់ដោយផ្នែកគ្រប់គ្រងតុលាការរបស់ អ.វ.ត.ក នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០៩។

[២៦] កំណត់ហេតុនៃការចូលខ្លួនដំបូង ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧ ឯកសារ D42 ទំព័រ២។

[២៧] កំណត់ហេតុនៃការសួរចម្លើយ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៩ ឯកសារ D285 កថាខណ្ឌ៤ និង ៩-១៣។

[២៨] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីរបស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨, ឯកសារ D99/3/42។

[២៩] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ៨៥ និង៨៨។

អន្តរជាតិ[៣០]។ អង្គបុរេជំនុំជម្រះក៏បានរកឃើញផងដែរថា យោងតាមបទដ្ឋានអន្តរជាតិ ជនត្រូវចោទត្រូវតែទទួលការជូនដំណឹងអំពីបទចោទទាំងអស់ ឬ បទចោទនីមួយៗដោយឡែកពីគ្នា ដែលដាក់បន្ទុកលើខ្លួនឱ្យបានត្រឹមត្រូវ "ត្រឹមកម្រិតមួយ ដែលអាចឱ្យជនទាំងនេះអនុវត្តនូវសិទ្ធិទាំងឡាយដែលផ្តល់ជូនខ្លួននៅក្នុងអំឡុងពេលស៊ើបអង្កេត ដែលក្នុងនោះរួមទាំងសិទ្ធិស្នើសុំបំពេញកិច្ចស៊ើបសួរស្របតាមវិធាន ៥៨(៦) នៃវិធានផ្ទៃក្នុង"[៣១]។

២៣. អង្គបុរេជំនុំជម្រះសង្កេតឃើញបន្ថែមទៀតថា យោងតាមបណ្តឹងឧទ្ធរណ៍ សហមេធាវីការពារក្តីជនត្រូវចោទបានតវ៉ាអំពីអត្ថិភាពនៃមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជនត្រូវចោទអាចទទួលខុសត្រូវលើឧក្រិដ្ឋកម្ម ដែលស្ថិតនៅក្រោមការស៊ើបអង្កេត ដោយសហមេធាវីការពារក្តីបានចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេតមិនបានផ្តល់ទម្ងន់ឱ្យបានសមរម្យលើភស្តុតាងដោះបន្ទុកដែលមាននៅក្នុងសំណុំរឿង។ ទាក់ទងនឹងចំណុចនេះ អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា យោងតាមដីកាសម្រេចបន្តឋិរវេលា សហចៅក្រមស៊ើបអង្កេតបានធ្វើការពិនិត្យមើលភស្តុតាង ដែលមាននៅក្នុងសំណុំរឿងឡើងវិញ ទាំងភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក[៣២]។ សហចៅក្រមស៊ើបអង្កេតបានពិចារណាលើសម្ភារៈ ដែលពាក់ព័ន្ធនៅក្នុងសំណុំរឿង ហើយបានសន្និដ្ឋានថា មូលហេតុដែលត្រូវបានរកឃើញនៅតែមានអត្ថិភាព។

២៤. ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនបានត្រឹមត្រូវ នៅពេលពិចារណាថា "មូលហេតុដែលត្រូវបានរកឃើញ"នៅតែមានអត្ថិភាព។

២៥. នៅពេលពិនិត្យពិចារណាលើសំណុំរឿងឡើងវិញ អង្គបុរេជំនុំជម្រះបានរកឃើញថា មានចម្លើយនិងឯកសារថ្មីៗនៅក្នុងសំណុំរឿង ដែលមានលក្ខណៈជាភស្តុតាងដាក់បន្ទុក[៣៣]។ ក្រោយពីធ្វើ

[៣០] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ៦០-៨៥។
[៣១] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ១៣៨។
[៣២] ដីកាសម្រេចបន្តឋិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ១៨-២១។
[៣៣] [redacted]

ការពិនិត្យមើលភស្តុតាងទាំងអស់ អង្គបុរេជំនុំជម្រះមិនបានរកឃើញថា នៅក្នុងដំណាក់កាលនេះ ភស្តុតាងដោះបន្ទុកថ្មីៗនឹងមានទម្ងន់ជាងការសន្និដ្ឋានដែលថា មានហេតុផលដែលត្រូវបានរកឃើញនោះឡើយ។

២៦. អង្គបុរេជំនុំជម្រះយល់ឃើញថា វាមិនត្រឹមតែមាន"មូលហេតុដែលត្រូវបានរកឃើញ" ដែលនឹងធ្វើឱ្យអ្នកសង្កេតការណ៍ដោយអព្យាក្រឹតជឿថា ជនត្រូវចោទអាចធ្លាប់បានប្រព្រឹត្ត ឬ អាចត្រូវទទួលខុសត្រូវលើឧក្រិដ្ឋកម្មទាំងឡាយ ដែលបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដូចដែលសហចៅក្រមស៊ើបអង្កេតបានអះអាងនៅក្នុងដីកាសម្រេចបន្តឋិរវេលាប៉ុណ្ណោះទេ វាថែមទាំងមានភស្តុតាងបន្ថែមជាមូលដ្ឋានគាំទ្រផងដែរដល់ "មូលហេតុ ដែលត្រូវបានរកឃើញ" នៅក្នុងដំណាក់កាលនេះ។

២៧. ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា លក្ខខណ្ឌទីមួយ ដែលបង្គាប់ឱ្យមានការឃុំខ្លួនបណ្ដោះអាសន្ន ដូចបានចែងនៅក្នុងវិធាន ៦៣(៣)(ក) នៅតែបានបំពេញ។

**ខ. ការពិចារណាលើមូលដ្ឋាន ដែលធ្វើឱ្យការឃុំខ្លួនបណ្ដោះអាសន្នជាវិធានការដ៏ចាំបាច់មួយ (វិធាន៦៣(៣)(ខ)នៃវិធានផ្ទៃក្នុង)៖**

២៨. យោងតាមដីកាសម្រេចបន្តឋិរវេលា សហចៅក្រមស៊ើបអង្កេតបានចង្អុលយោងលើការរកឃើញរបស់អង្គបុរេជំនុំជម្រះនៅក្នុងសាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ **ខៀវ សំផន** ប្រឆាំងនឹងដីកា

[redacted]

សម្រេចបដិសេធសំណើសុំដោះលែងឱ្យមានសេរីភាព និងដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន[៣៤] ហើយសហចៅក្រមស៊ើបអង្កេតបានពិចារណាថា តើល័ក្ខខ័ណ្ឌដូចមានចែងនៅក្នុងវិធាន ៦៣(៣)(ខ) នៅតែបានបំពេញដែរឬយ៉ាងណា។ សហចៅក្រមស៊ើបអង្កេតបានរកឃើញថា ដោយសារតែមិនមានកាលៈទេសៈប្រែប្រួល ការឃុំខ្លួននៅតែជាវិធានការចាំបាច់ក្នុងការការពារសន្តិសុខរបស់ជនត្រូវចោទ និងក្នុងការរក្សាសណ្តាប់ធ្នាប់សាធារណៈ[៣៥]។

២៩. អង្គបុរេជំនុំជម្រះយល់ឃើញថា នៅពេលអនុវត្តបទដ្ឋាននេះ សហចៅក្រមស៊ើបអង្កេតបានបំពេញកិច្ចរបស់ខ្លួនបានត្រឹមត្រូវ។

**<u>ភាពចាំបាច់ក្នុងការរារាំងកុំឱ្យជនដែលត្រូវចោទនោះគាបសង្កត់ទៅលើសាក្សី និងបំផ្លាញភស្តុតាងក្នុងករណីមានការដោះលែងឱ្យមានសេរីភាព (វិធាន ៦៣(៣)(ខ)(i) និងវិធាន ៦៣(៣)(ខ)(ii) នៃវិធានផ្ទៃក្នុង) ដើម្បីធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី (វិធាន ៦៣(៣)(ខ)(iii) នៃវិធានផ្ទៃក្នុង)៖</u>**

៣០. អង្គបុរេជំនុំជម្រះសង្កេតឃើញថា តាមលក្ខណៈជាក់ស្តែង សហមេធាវីការពារក្តីមិនយល់ស្រប[៣៦] ជាមួយនឹងសម្អាងហេតុរបស់អង្គបុរេជំនុំជម្រះចំពោះការពិចារណាអំពីហានិភ័យថ្មីៗ ដែលពាក់ព័ន្ធនឹងវិធាន៦៣(៣)(ខ)(i) ដល់ វិធាន៦៣(៣)(ខ)(iii) ដូចបានសម្រេចនៅក្នុងសាលដីកាលើការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២00៩[៣៧]។ អង្គបុរេជំនុំជម្រះយល់ឃើញថា ការរកឃើញរបស់ខ្លួនមុនៗមិនមែនជាកម្មវត្ថុនៃការការពិភាក្សាបន្ថែមទៀតនោះឡើយ លើកលែងតែលក្ខខណ្ឌទាំងឡាយដែលទាមទារចំពោះការពិនិត្យសេចក្តីសម្រេចទាំងឡាយ



[៣៤] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ពីររបស់ ខៀវ សំផន។

[៣៥] ដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ២២-២៨។

[៣៦] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១៤-១៥។

[៣៧] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ពីររបស់ ខៀវ សំផន កថាខណ្ឌ៤0-៥៩។

ឡើងវិញបានបំពេញ[៣៨]។ ដូច្នេះអង្គបុរេជំនុំជម្រះនឹងមិនធ្វើការពិភាក្សាលើទឡ្ហីករណ៍ទាំងឡាយ ដែលបានលើកឡើងឡើយ។

៣១. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញទៀតថា នៅក្នុងដីកាសម្រេចដែលបានប្តឹងឧទ្ធរណ៍ សហចៅក្រមស៊ើបអង្កេតមិនបានចាត់ទុកថា ការឃុំខ្លួននៅតែជាវិធានការចាំបាច់មួយក្នុងការរារាំងកុំឱ្យជនត្រូវចោទគាបសង្កត់ទៅលើសាក្សី និងបំផ្លាញភស្តុតាង ក្នុងករណីមានការដោះលែងឱ្យមានសេរីភាព និង/ឬ ដើម្បីធានានូវអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធីឡើយ។

***<u>ភាពចាំបាច់ក្នុងការការពារសន្តិសុខរបស់ជនត្រូវចោទ (វិធាន ៦៣(៣)(ខ)(iv) នៃវិធានផ្ទៃក្នុង)៖</u>***

៣២. សហមេធាវីការពារក្តីបានផ្តល់អំណះអំណាងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួនថា សហចៅក្រមស៊ើបអង្កេតមិនបានផ្តល់ភស្តុតាងនៃការគម្រាមកំហែងជាក់ស្តែង ដែលកើតមាននាពេលបច្ចុប្បន្នលើសុវត្ថិភាពរបស់ជនត្រូវចោទ ប្រសិនបើជននេះត្រូវបានដោះលែងឱ្យមានសេរីភាព[៣៩]។ សហមេធាវីការពារក្តីបានសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតបានផ្អែកដោយមិនសមស្របលើហេតុការណ៍ធ្ងន់ធ្ងរ និងការគម្រាមកំហែង ដែលបានកើតឡើងនៅពេលអតីតកាលលើជនត្រូវចោទផ្សេងទៀត ក្នុងគោលបំណងបង្ហាញអំពីការគម្រាមកំហែងលើសុវត្ថិភាពរបស់ជនត្រូវចោទ[៤០]។ សហមេធាវីការពារក្តីបានសន្និដ្ឋានថា ជនត្រូវចោទ"ខ្លួនឯងមិនមានការព្រួយបារម្ភអំពីសន្តិសុខរបស់ខ្លួន" នោះទេ[៤១] ហើយបានគូសបញ្ជាក់ថា ការវាយប្រហារបានកើតឡើងយូរមកហើយតាំងពីឆ្នាំ១៩៩១ ហើយខ្លួនបានរស់នៅក្នុងសង្គមនេះ ដោយសន្តិភាពក្នុងរយៈពេលដប់ឆ្នាំដោយគ្មានហេតុការណ៍អ្វីផ្សេងទៀតបានកើតឡើង[៤២]។

---

[៣៨] សេចក្តីសម្រេចលើពាក្យសុំពិចារណាសារជាថ្មីអំពីសិទ្ធិដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯង ឯកសារ C22/I/68 ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ កថាខណ្ឌ២៥។

[៣៩] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១៧-១៨។

[៤០] សេចក្តីដំទាស់នឹងការបន្តថិរវេលានៃការឃុំខ្លួនជាបណ្តោះអាសន្នលោក ខៀវ សំផន ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៨ ឯកសារ C26/7 (សេចក្តីដំទាស់) កថាខណ្ឌ១៣-១៥។

[៤១] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ១៧ និង សេចក្តីដំទាស់ កថាខណ្ឌ១៥។

[៤២] ប្រតិចារឹកនៃសវនាការលើបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៩ ឯកសារ C26/9 ទំព័រ២២។

៣៣. សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា ការរកឃើញរបស់អង្គបុរេជំនុំជម្រះនៅក្នុងបណ្តឹងឧទ្ធរណ៍លើកមុនទាក់ទងនឹងសន្តិសុខរបស់ជនត្រូវចោទនៅតែមានសុពលភាព ដោយសារតែកាលៈទេសៈពាក់ព័ន្ធមិនមានការផ្លាស់ប្តូរជាប្រយោជន៍ដល់ការដោះលែង ហើយសហព្រះរាជអាជ្ញាបានចង្អុលបញ្ជាក់ថា "ដើមបណ្តឹងឧទ្ធរណ៍មិនបានផ្តល់ភស្តុតាងបង្ហាញថា ការរកឃើញរបស់[សហចៅក្រមស៊ើបអង្កេត]លើបញ្ហានេះពិតជាមានកំហុស"[៤៣]។ តាមការពិតទៅ សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា ភស្តុតាងថ្មីៗនៃការគម្រាមកំហែងដល់សន្តិសុខរបស់ជនត្រូវចោទបែបនេះបានលេចចេញនាពេលថ្មីៗ ដូចដែលបានឆ្លុះបញ្ចាំងនៅក្នុងសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងលេខ ០០១[៤៤]។

៣៤. អង្គបុរេជំនុំជម្រះបានសង្កេតឃើញថា ខ្លួនបានរកឃើញនៅក្នុងសាលដីការបស់ខ្លួនចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៨ថា សន្តិសុខរបស់ជនត្រូវចោទមិនអាចធានាបានឡើយ ក្នុងករណីដោះលែងឱ្យមានសេរីភាព។ ហេតុការណ៍ជាច្រើនក្នុងរយៈពេលម្ភៃឆ្នាំកន្លងមកនេះ ផ្តល់ជាភស្តុតាងនៃការគម្រាមកំហែងជាក់ស្តែង និងពិតប្រាកដដល់សន្តិសុខរបស់ជនត្រូវចោទ[៤៥]។ បន្ថែមពីនេះ ដូចដែលសហព្រះរាជអាជ្ញាបានអះអាង ដំណាក់កាលនីតិវិធីចុងក្រោយនៅក្នុងសំណុំរឿងលេខ ០០១ និងការចេញសាលក្រមនាពេលខាងមុខ បង្កើតជាសក្តានុភាពចំពោះប្រតិកម្មធ្ងន់ធ្ងរបន្ថែមដល់ជនត្រូវចោទ។ នៅក្នុងបណ្តឹងឧទ្ធរណ៍លើកមុន ទោះបីជាពេលវេលាកន្លងផុតនេះត្រូវបានអង្គបុរេជំនុំជម្រះច្រានចោលដោយចាត់ទុកថា ជាស្ថានសម្រាលទោសក៏ដោយ គេកត់សម្គាល់ឃើញថា ក្រុមមេធាវីការពារក្តីមិនបានផ្តល់ភស្តុតាងនៅក្នុងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់របស់ខ្លួនដើម្បីគាំទ្រដល់ការអះអាងថា ជនត្រូវចោទនឹងមានសន្តិសុខ ប្រសិនបើមានការដោះលែងឱ្យមានសេរីភាព។

[៤៣] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១៤។

[៤៤] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១៥-១៦។

[៤៥] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ពីររបស់ ខៀវ សំផន កថាខណ្ឌ៥៣-៥៤។

00505880



៣៥. អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានត្រឹមត្រូវថា ការឃុំខ្លួនបណ្តោះអាសន្ននៅតែមានភាពចាំបាច់ដើម្បីការពារសន្តិសុខរបស់ជនត្រូវចោទ អនុលោមតាមវិធាន ៦៣(៣)(ខ)(iv) នៃវិធានផ្ទៃក្នុង។

**ភាពចាំបាច់ក្នុងការធានាសណ្តាប់ធ្នាប់សាធារណៈ (វិធាន ៦៣(៣)(ខ)(v) នៃវិធានផ្ទៃក្នុង)៖**

៣៦. សហមេធាវីការពារក្តីបានសន្និដ្ឋានថា សហចៅក្រមស៊ើបអង្កេតមិនបានផ្តល់សម្អាងហេតុជាក់លាក់នៅពេលធ្វើការសម្រេចថា ការឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ននៅតែជាវិធានការចាំបាច់ក្នុងការធានាសណ្តាប់ធ្នាប់សាធារណៈ ដោយបានតវ៉ាថា ការព្រួយបារម្ភតាមការសន្និដ្ឋានទូទៅអំពីផលវិបាកផ្នែកចិត្តសាស្ត្រលើជនរងគ្រោះ ដោយសារកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.កមិនអាចយកមកដាក់សង្កត់លើជនត្រូវចោទបានឡើយ[៤៦]។ សហមេធាវីការពារក្តីចង្អុលយោងលើការដោះលែងជនជាប់ចោទបណ្តោះអាសន្ន ដើម្បីរង់ចាំការជំនុំជម្រះនៅICTY និងការខ្វះភស្តុតាងបង្ហាញអំពីអត្ថិភាពនៃជំងឺប៉ះទង្គិចផ្លូវចិត្ត ដែលកំពុងកើតឡើងលើប្រជាពលរដ្ឋកម្ពុជាដោយសារហេតុផលដោះលែងជនត្រូវចោទឱ្យមានសេរីភាព[៤៧]។

៣៧. នៅក្នុងពេលសវនាការ សហព្រះរាជអាជ្ញាបានច្រានចោលការប្រៀបធៀបរបស់ក្រុមមេធាវីការពារក្តីអំពីការដោះលែងជនជាប់ចោទនៅ ICTY ឱ្យមានសេរីភាពជាបណ្តោះអាសន្ន ដោយបានលើកឧទាហរណ៍មួយ ដែលគេបានដោះលែងជនជាប់ចោទឱ្យមានសេរីភាពមែន ប៉ុន្តែមិនមែនដោះលែងឱ្យទៅប្រទេសដែលឧក្រិដ្ឋកម្មដូចដែលបានចោទប្រកាន់ថាបានប្រព្រឹត្តនោះឡើយ[៤៨]។ សហព្រះរាជអាជ្ញាក៏បានសន្និដ្ឋានថា អបជ បានរកឃើញនៅក្នុងសាលដីការបស់ខ្លួនចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៨ អំពីហានិភ័យដល់សណ្តាប់ធ្នាប់សាធារណៈ ហើយ"ដើមបណ្តឹងឧទ្ធរណ៍មិនបានផ្តល់ភស្តុតាងអ្វីថ្មីដែលអាចឱ្យ អបជ ច្រានចោលការរកឃើញរបស់ខ្លួនកាលពីលើកមុន"នោះឡើយ[៤៩]។

---

[៤៦] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ២០-២២។

[៤៧] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ២២-២៣។

[៤៨] ប្រតិចារិកនៃសវនាការលើបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ C26/9 ទំព័រ៤៧។

[៤៩] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១៨។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

សហព្រះរាជអាជ្ញាក៏បានលើកឡើងទៀតថា សក្ខីកម្មរបស់អ្នកជំនាញផ្នែកចិត្តសាស្ត្រនៅក្នុងសំណុំរឿងលេខ០០១ នៅក្នុងខែសីហា ឆ្នាំ២០០៩ បានផ្តល់ជាភស្តុតាងថ្មីអំពីជំងឺប៉ះទង្គិចផ្លូវចិត្ត និងផលវិបាកផ្នែកចិត្តសាស្ត្រលើអ្នកដែលនៅរស់រានមានជីវិត និងប្រជាពលរដ្ឋកម្ពុជាទាំងអស់ ដោយសារកិច្ចដំណើរការនីតិវិធី ក្នុងនោះរួមទាំងការសម្តែងនូវការបដិសេធមិនទទួលខុសត្រូវរបស់ជនត្រូវចោទ[៥០]។ នៅពេលពិចារណាលើកត្តាទាំងនេះ តាមរយៈភស្តុតាងនៃស្ថានភាពសន្តិសុខទូទៅរបស់ព្រះរាជាណាចក្រកម្ពុជា សហព្រះរាជអាជ្ញាបានសន្និដ្ឋានថា ការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការចាំបាច់ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ[៥១]។

៣៨. អង្គបុរេជំនុំជម្រះសង្កេតឃើញថា សហមេធាវីការពារក្តីមិនបានដាក់ជូននូវឯកសារគាំទ្រដល់ទឡ្ហីករណ៍របស់ខ្លួនទាក់ទិននឹងស្ថេរភាព និង/ឬ សុខភាពផ្លូវចិត្តរបស់ប្រជាពលរដ្ឋកម្ពុជានៅក្នុងបណ្តឹងឧទ្ធរណ៍ ឬ ក្នុងអំឡុងពេលសវនាការនាថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១០ ឡើយ។ អង្គហេតុដែលបានដាក់ជូននៅក្នុងសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាគាំទ្រដល់សេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតដែលថាការដោះលែងជនត្រូវចោទនឹងពិតជាធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។

៣៩. អង្គបុរេជំនុំជម្រះយល់ឃើញថា សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានត្រឹមត្រូវថា វានៅតែមានភាពចាំបាច់ក្នុងការឃុំខ្លួនជនត្រូវចោទដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ។

## គ. ការយកចិត្តទុកដាក់សមគួររបស់សហចៅក្រមស៊ើបអង្កេត៖

៤០. យោងតាមដីកាសម្រេចបន្តថិរវេលា សហចៅក្រមស៊ើបអង្កេតបានទទួលស្គាល់ថា "ការកន្លងទៅនៃពេលវេលាចាប់តាំងពីពេលឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន គឺមានការជាប់ពាក់ព័ន្ធនឹងការសម្រេចអំពីនីត្យានុកូលភាពក្នុងការបន្តឃុំខ្លួនជននេះបណ្តោះអាសន្នបន្តទៀត"[៥២]។ សហចៅក្រម

[៥០] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ១៩។ ប្រតិចារឹកនៃសវនាការលើបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃ១២ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ C26/9 ទំព័រ៤៧-៤៩។

[៥១] ប្រតិចារឹកនៃសវនាការលើបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ C26/9 ទំព័រ៤៩-៥០។

[៥២] ដីកាសម្រេចបន្តថិរវេលា កថាខណ្ឌ២៩។



ECCC * CETC
CHAMBER

ស៊ើបអង្កេត បានចង្អុលបញ្ជាក់ថា វិសាលភាពនៃការស៊ើបអង្កេតដូចដែលបានទាមទារនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់លើជនត្រូវចោទនៅក្នុងដីកានោះ ទាមទារឱ្យមានកិច្ចស៊ើបសួរដែលមានទំហំធំធេង[៥៣]។ សហចៅក្រមស៊ើបអង្កេតបានលើកឡើងបន្ថែមនៅក្នុងដីកាសម្រេចបន្តថិរវេលា អំពីកិច្ចស៊ើបសួរដែលបានបំពេញចាប់តាំងពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលក្នុងនោះរួមបញ្ចូលកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី និងឯកសារផ្សេងទៀត ដែលបានដាក់បន្ថែមចូលទៅក្នុងសំណុំរឿងតាមសំណើរបស់ភាគី ឬ តាមគំនិតផ្តួចផ្តើមរបស់សហចៅក្រមស៊ើបអង្កេត[៥៤]។

៤១. សហមេធាវីការពារក្តីបានអះអាងថា សហចៅក្រមស៊ើបអង្កេតមិនបានបំពេញកិច្ចដោយយកចិត្តទុកដាក់នៅក្នុងកិច្ចស៊ើបសួររបស់ខ្លួន ដោយបានដាក់បញ្ចូលកំណត់ហេតុនៃការស្តាប់ចម្លើយចំនួនតែសាមសិបប៉ុណ្ណោះទៅក្នុងសំណុំរឿងចាប់តាំងពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៨[៥៥]។ មិនតែប៉ុណ្ណោះ សហមេធាវីការពារក្តីបានសន្និដ្ឋានថាសហចៅក្រមស៊ើបអង្កេតមិនបាន"ឆ្លើយតបទៅនឹងទឡ្ហីករណ៍របស់ក្រុមមេធាវីការពារក្តីស្តីពីការរំលោភបំពានជាប្រព័ន្ធលើសច្ចធារណ៍និរទោស និងសិទ្ធិទាំងឡាយរបស់ **ខៀវ សំផន**..."[៥៦]។ យោងតាមសហមេធាវីការពារក្តី ការធ្វើបែបនេះបង្ហាញជាភស្តុតាង "យ៉ាងច្បាស់អំពីភាពលម្អៀងជាប្រព័ន្ធ" ដែលជនត្រូវចោទទទួលរង ហើយការធ្វើបែបនេះ គឺជាការមិនយកចិត្តទុកដាក់សមគួរពីសំណាក់សហចៅក្រមស៊ើបអង្កេតនៅក្នុងការបំពេញកិច្ចស៊ើបសួររបស់ខ្លួន[៥៧]។

៤២. សហព្រះរាជអាជ្ញាបានឆ្លើយតបថា តាមការពិត សហចៅក្រមស៊ើបអង្កេតបានបង្កើនការរីកចម្រើនយ៉ាងច្រើននៅក្នុងកិច្ចស៊ើបសួររបស់ខ្លួន ដូចជា សហចៅក្រមស៊ើបអង្កេតបានជូនដំណឹង

---

[៥៣] ដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ៣០។

[៥៤] ដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ៣១។

[៥៥] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ២៧។

[៥៦] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៣១។

[៥៧] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៣២-៣៣។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C * C.E.T.C

00505883



ដល់ជនត្រូវចោទអំពីបទល្មើសដែលជននេះអាចរងការចោទប្រកាន់បន្ថែម[៥៨]។ សហព្រះរាជអាជ្ញាបានសន្និដ្ឋានបន្ថែមទៀតថា ដោយពិចារណាលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មទាំងនេះ និងភាពស្មុគស្មាញនៃរឿងក្តី រយៈពេលនៃការឃុំខ្លួនមានលក្ខណៈសមរម្យ ហើយក្រុមមេធាវីការពារក្តីមិនអាចលើកឡើងដោយមិនសមរម្យថា បញ្ហាទាំងឡាយដែលបានសម្រេចរួចហើយ ឬ ដែលរង់ចាំការសម្រេចនោះ គឺជាភស្តុតាងបញ្ជាក់អំពីការខ្វះការយកចិត្តទុកដាក់សមគួរ និងជាមូលដ្ឋានសម្រាប់ការដោះលែងបណ្តោះអាសន្នឡើយ[៥៩]។

៤៣. អង្គបុរេជំនុំជម្រះយោងទៅលើ បញ្ជាក់ឡើងវិញ និងតម្កល់ការរកឃើញជារួម និងសេចក្តីសង្កេតរបស់ខ្លួនលើភាពសមស្របនៃរយៈពេលឃុំខ្លួន ដែលបានសម្រេចនៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើសុំដោះលែងឱ្យមានសេរីភាព និងដីកាសម្រេចលើការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន[៦០]។

៤៤. អង្គបុរេជំនុំជម្រះយល់ឃើញទៀតថា ភាពសមស្របនៃរយៈពេលឃុំខ្លួន និងការយកចិត្តទុកដាក់របស់សហចៅក្រមស៊ើបអង្កេតនៅក្នុងការបំពេញកិច្ចស៊ើបសួរគឺ ជាកត្តាដែលត្រូវយកមកធ្វើការពិចារណា នៅពេលអនុវត្តអំណាចឆន្ទានុសិទ្ធិក្នុងការបន្តការឃុំខ្លួនបណ្តោះអាសន្ន។

៤៥. ចំពោះសេចក្តីសង្កេតរបស់សហមេធាវីការពារក្តីថា មានកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីតែចំនួនសាមសិបបានដាក់ចូលទៅក្នុងសំណុំរឿងចាប់តាំងពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២00៩ អង្គបុរេជំនុំជម្រះសង្កេតឃើញថា សហមេធាវីការពារក្តីមានការយល់ខុសនូវការលើកឡើងរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងដីកាសម្រេចបន្តថិរវេលា។ នៅពេលដែលយើងអានកថាខណ្ឌ ៣១ និងកថាខណ្ឌ ១៨ នៅក្នុងដីកាសម្រេចបន្តថិរវេលារួមគ្នា វាបង្ហាញយ៉ាងច្បាស់ថា ចម្លើយសាក្សីជាច្រើន និងភស្តុតាងដទៃទៀតបានដាក់បន្ថែមចូលទៅក្នុងសំណុំរឿងចាប់តាំងពីថ្ងៃទី២៧ ខែកុម្ភៈ




[៥៨] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ២0។

[៥៩] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ២១-២៣។

[៦០] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ពីររបស់ ខៀវ សំផន កថាខណ្ឌ៦៨-៧៥។

00505884



ឆ្នាំ២០០៩។ ក្នុងចំណោមសំណុំភស្តុតាងថ្មីៗទាំងអស់នេះ សហចៅក្រមស៊ើបអង្កេតបានចាត់ទុកចម្លើយសាក្សីតែចំនួនសាមសិបប៉ុណ្ណោះថា ជាចម្លើយដាក់បន្ទុក។

៤៦. អង្គបុរេជំនុំជម្រះយល់ឃើញថា មានភស្តុតាងបន្ថែមគ្រប់គ្រាន់ ដោយក្នុងនោះមានកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី សៀវភៅ ឯកសារផ្ទៃក្នុងរបស់បក្សកម្មុយនីស្តកម្ពុជា និងទូរសារ ដែលជនត្រូវចោទបានទទួល និងកម្រងឯកសារសារព័ត៌មានថ្មីៗនៅក្នុងសំណុំរឿងបង្ហាញថា ការស៊ើបអង្កេតបានវិវត្តទៅមុខយ៉ាងលឿនក្នុងអំឡុងពេលនៃការពិចារណានេះ។ សហចៅក្រមស៊ើបអង្កេតបានផ្តល់សម្អាងហេតុគ្រប់គ្រាន់នៅក្នុងដីកាសម្រេចបន្តឋិរវេលា ដើម្បីជាការគាំទ្រដល់ការរកឃើញនេះ។

៤៧. អង្គបុរេជំនុំជម្រះយល់ឃើញថា ភាពធ្ងន់ធ្ងរ និងលក្ខណៈនៃឧក្រិដ្ឋកម្ម ដែលចោទប្រកាន់លើជនត្រូវចោទទាមទារឱ្យមានកិច្ចស៊ើបសួរមួយដែលមានទំហំធំធេង ដែលបានបំពេញរួចហើយ។ អង្គបុរេជំនុំជម្រះយល់ឃើញថា នៅពេលពិចារណាលើវិសាលភាព និងដំណាក់កាលស៊ើបអង្កេតនៅពេលបច្ចុប្បន្ននេះ សហចៅក្រមស៊ើបអង្កេតបានប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនយ៉ាងសមហេតុផល នៅពេលចេញដីកាសម្រេចបន្តឋិរវេលានៃការឃុំខ្លួន។

## ឃ. សំណើសុំដោះលែងដោយដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ៖

៤៨. យោងតាមបណ្តឹងឧទ្ធរណ៍ សហមេធាវីការពារក្តីបានស្នើសុំអង្គបុរេជំនុំជម្រះឱ្យបង្គាប់ដោះលែងជនត្រូវចោទ[៦១] ហើយនៅក្នុងពេលធ្វើសវនាការដេញដោល សហមេធាវីការពារក្តីបានបញ្ជាក់ថា តុលាការអាចដាក់លក្ខខណ្ឌនៃការដោះលែងឱ្យមានសេរីភាពបែបនេះបាន ដើម្បីធានាសុវត្ថិភាពជនត្រូវចោទ និងដើម្បីបញ្ជាក់ទីកន្លែងរបស់ជននេះនៅគ្រប់ពេលទាំងអស់[៦២]។

៤៩. អង្គបុរេជំនុំជម្រះយល់ឃើញថា សំណើសុំដោះលែងឱ្យមានសេរីភាពមានទម្ងន់តិចជាងភាពចាំបាច់ក្នុងការឃុំខ្លួនជនត្រូវចោទ។

---

[៦១] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ៣៥។

[៦២] ប្រតិចារិកនៃសវនាការលើបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១០ ឯកសារ C26/9 ទំព័រ១៩។



E.C.C.C * C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

00505885

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ៣៦)

លេខ/No.C26/9/12

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទៈ**

១. ទទួលយកបណ្តឹងឧទ្ធរណ៍នេះថា ត្រឹមត្រូវតាមទម្រង់។

២. តម្កល់ដីកាសម្រេចបន្តឋិរវេលារបស់សហចៅក្រមស៊ើបអង្កេត ដោយយកផ្នែកសម្អាងហេតុដូចបានលើកឡើងនៅក្នុងកថាខណ្ឌ ៣៤ នៃសាលដីកានេះ ដាក់បន្ថែមលើសម្អាងហេតុរបស់សហចៅក្រមស៊ើបអង្កេត។

៣. បដិសេធសំណើសុំដោះលែងឱ្យមានសេរីភាព។

៤. បដិសេធបណ្តឹងឧទ្ធរណ៍នេះចោលទុកជាឥតបានការ។

សាលដីកានេះបិទផ្លូវតវ៉ា អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង ។

សាលដីកានេះ **ប្រកាសជាសាធារណៈ** ដោយអង្គបុរេជំនុំជម្រះ កំបាំងមុខជនត្រូវចោទ និងសហមេធាវីការពារក្តីរបស់ជនត្រូវចោទ។

**ភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០១០**

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

**Rowan DOWNING** **នីយ ធុល** **Katinka LAHUIS** **ហួត វុទ្ធី** **ប្រាក់ គឹមសាន**

**Entela JOSIFI** **ឈន ព្រលឹង**